ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០១៥/២៣ ក.ប/ស.ជ.ណ.ផ.ព

# សេចក្តីជូនដំណឹង
## ស្តីពី
## ការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុនផ្នែកថែទាំ សម្រាប់ពលករជំនាញ ដើម្បីទៅធ្វើការនៅប្រទេសជប៉ុន

យោងតាមការជូនដំណឹងពីក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងទៅធ្វើការនៅប្រទេសជប៉ុន ក្នុងគម្រោងពលករជំនាញ ឱ្យបានជ្រាបថាអង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន នឹងរៀបចំការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុនផ្នែកថែទាំ តាមរយៈប្រព័ន្ធកុំព្យូទ័រ (CBT) ក្នុងគម្រោងពលករជំនាញ ដែលមានព័ត៌មានលម្អិត ដូចខាងក្រោម៖

| ល.រ | ប្រភេទតេស្ត | កាលបរិច្ឆេទធ្វើតេស្ត | មណ្ឌល | តម្លៃចុះឈ្មោះ |
|---|---|---|---|---|
| ១ | ផ្នែកថែទាំ | ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣<br>ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៣<br>ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣<br>ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣<br>ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៣<br>ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២៣ | វិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI) | ១៤ដុល្លារ |

- លក្ខខណ្ឌចុះឈ្មោះធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន គឺចាប់ពីអាយុ ១៧ឆ្នាំឡើងទៅ ដោយមិនគិតពីកម្រិតវប្បធម៌
- ពិន្ទុធ្វើតេស្តជាប់ជាស្ថាពរ៖ ចាប់ពី ៦០% ឡើងទៅ
- ចំនួនបេក្ខជនដែលអាចទទួលសម្រាប់ការស្នើសុំធ្វើតេស្តបាន ៥០នាក់
- សម្រាប់ព័ត៌មានលម្អិត និងការចុះឈ្មោះ សូមចូលមើលគេហទំព័រ https://ac.prometricjp.com/testlist/nc/nursingcare_cambodia.html
- ព័ត៌មានមណ្ឌលសម្រាប់ធ្វើតេស្តមានដូចខាងក្រោម៖
  - ❖ វិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ (EDI)
    - អាសយដ្ឋាន៖ ផ្ទះលេខ៥A ផ្លូវលេខ៣៧០ សង្កាត់បឹងកេងកង១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
    - លេខទូរស័ព្ទ៖ +855 12 937 168 / +855 16 862 868 / +855 15 729 123 / +855 12 269 768
- សេវានៃការចុះឈ្មោះធ្វើតេស្តគឺបង់ជូនទៅអង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន

- **ឯកសារចាំបាច់ដែលត្រូវយកមកជាមួយនៅថ្ងៃធ្វើតេស្តៈ** លិខិតឆ្លងដែន ឬប័ណ្ណបើកបរ

**បញ្ជាក់ៈ** កាលបរិច្ឆេទនៃការធ្វើតេស្តនេះ អាចនឹងផ្លាស់ប្តូរអាស្រ័យទៅតាមស្ថានភាពជាក់ស្តែង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់ និងសាធារណជនដែលមានបំណងចង់ចុះឈ្មោះធ្វើតេស្តភាសា និងតេស្តជំនាញសម្រាប់ផ្នែកថែទាំ ជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ១១កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូនៈ**

-សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA)

-សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC)

-ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់

“ដើម្បីផ្សព្វផ្សាយ”

-ឯកសារ-កាលប្បវត្តិ